# ក្រុមអង្គការសង្គមស៊ីវិលស្នើឱ្យរដ្ឋាភិបាលកម្ពុជា បញ្ចប់និទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន

ដោយ ហ៊ុំ ចំរើន

2024.11.01




ក្រុមអង្គការសង្គមស៊ីវិល ចំនួន ២១ស្ថាប័ន ស្នើឱ្យរដ្ឋាភិបាលកម្ពុជាបញ្ចប់និទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មប្រឆាំងលើអ្នកសារព័ត៌មាន។ ការស្នើសុំនេះ ធ្វើឡើងតាមរយៈសេចក្តីថ្លែងការណ៍រួម ចេញនៅថ្ងៃទី១ ខែវិច្ឆិកាក្នុងទិវាអន្តរជាតិ ដើម្បីបញ្ចប់និទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន។ក្រុមអង្គការសង្គមស៊ីវិលទាំងនោះ រួមមាន សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ជាដើម បានអំពាវនាវដល់រដ្ឋាភិបាលធានានូវការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ចំពោះឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។

យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន ១៥នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៤ មក ហើយពួកគេនៅមិនទាន់ទទួលបានយុត្តិធម៌នៅឡើយ។ ក្នុងនោះ អ្នកសារព័ត៌មានចំនួន ១២នាក់បានរាយការណ៍អំពីបញ្ហារសើបមុនពេលពួកគេត្រូវបានសម្លាប់។ ការយាយី និងការគំរាមកំហែងលើអ្នកសារព័ត៌មាននៅតែជាក្តីបារម្ភនៅឆ្នាំ២០២៤ នេះ។

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) កត់ត្រាថា អ្នកសារព័ត៌មាន ចំនួន ៤៦នាក់ បានរងការយាយីក្នុងរយៈពេល ៩ខែ ក្នុងឆ្នាំ២០២៤ ចាប់ពីខែមករា ដល់ខែកញ្ញាឆ្នាំ២០២៤។ អ្នកសារព័ត៌មានទាំង ៤៦

នាក់នេះ មានអ្នកសារព័ត៌មាន ៣៤នាក់ ប្រឈមនឹងការឃាយឃីតាមផ្លូវតុលាការ ដែលរួមបញ្ចូលការកោះហៅមកសាកសួរ ការកោះហៅមកបង្ហាញខ្លួននៅតុលាការ និងការឃាត់ខ្លួន។

បន្ថែមពីនោះ អ្នកសារព័ត៌មានចំនួន ៧នាក់ រងនូវការបៀតបៀនលើរាងកាយ និងអ្នកសារព័ត៌មាន ចំនួន ៥នាក់ទៀត ប្រឈមនឹងការរឹតត្បិតក្នុងការបំពេញ ការងាររបស់ខ្លួន។ ក្នុងនោះ អាជ្ញាប័ណ្ណសារព័ត៌មានចំនួន៣ ត្រូវបានដកហូត។

ក្រុមអង្គការស៊ីវិលរកឃើញថា និទ្ទណ្ឌភាពបែបនេះមិនមែនកើតមាន ចំពោះតែអ្នកសារព័ត៌មានប៉ុណ្ណោះទេ។ ជាក់ស្តែង កង្វះខាតនូវការស៊ើបអង្កេត និងនីតិវិធីព្រហ្មទណ្ឌត្រឹមត្រូវ ក្នុងករណីឃាតកម្មលើសកម្មជនបរិស្ថាន លោក ឈុត វុទ្ធី សកម្មជនសហជីព លោក ជា វិជ្ជា និងលោក រស់ សុវណ្ណារ៉េត អ្នកវិភាគនយោបាយបណ្ឌិត កែម ឡី ជាដើម។ ករណីនេះ កាន់តែបង្ហាញពីការរីករាលដាល នៃវប្បធម៌និទ្ទណ្ឌភាព ដែលមាននៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណា ក្រុមអង្គការសង្គមស៊ីវិលថា នេះគ្រាន់តែជាផ្នែកមួយនៃករណីជាច្រើនទៀត ដែលបានកើតឡើង ប៉ុន្តែ មិនត្រូវបាន អាជ្ញាធរពាក់ព័ន្ធដោះស្រាយនោះទេ។

នៅថ្ងៃទី១ ខែវិច្ឆិកា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា និងអង្គការ យូណេស្កូ (UNESCO) ប្រចាំនៅប្រទេសកម្ពុជា ក៏បានរៀបចំសន្និសីទមួយផងដែរ ក្នុងឱកាសទិវាអន្តរជាតិ ដើម្បីបញ្ចប់និទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន។ សន្និសីទនេះមានអ្នកចូលប្រមាណ១៥០ ហើយ មានទាំងតំណាងអង្គការស៊ីវិល និង តំណាងរដ្ឋាភិបាលចូលរួមផងដែរ។

តំណាងប្រចាំប្រទេសនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅប្រទេសកម្ពុជា អ្នកស្រី រួអេដា អិលហាច (Rouei da El Hage) បានលើកឡើងក្នុងសន្និសីទថា បញ្ហានិទ្ទណ្ឌភាពប្រឆាំងលើអ្នកសារព័ត៌មាន បានជះឥទ្ធិពលអាក្រក់ដល់សិទ្ធិទទួលបាននូវព័ត៌មានចម្រុះ និងប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពបញ្ចេញមតិរបស់ពលរដ្ឋ នៅលើពិភពលោក។ អ្នកស្រីថា អ្នកសារព័ត៌មាន គឺជាអ្នកនាំសារដ៏សំខាន់ ដើម្បីជំរុញឱ្យអាជ្ញាធរដ្ឋនីមួយៗ ទទួលខុសត្រូវ និងដោះស្រាយបញ្ហា។

ជុំវិញរឿងនេះ អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លោក ស្រ៊ាង ចិន្តា ដែលបានចូលរួមក្នុងសន្និសីទដែរនោះ បានលើកឡើងថា បច្ចុប្បន្ន កម្ពុជាគ្មានអំពើនិទ្ទណ្ឌភាពមកអ្នកសារព័ត៌មាននោះទេ។ លោកបន្តថា កម្ពុជាបានប្រឹងប្រែងលើកកម្ពស់ សេរីភាពសារព័ត៌មាន និងសេរីភាព បញ្ចេញមតិ របស់ពលរដ្ឋស្មើភាព និងគ្មានការរឹតត្បិតដូចបណ្តាអង្គការក្រៅរដ្ឋាភិបាលមួយចំនួនលើកឡើងនោះទេ។

លោក ស្រ៊ាង ចិន្តា៖ *«បច្ចុប្បន្នយើងអាចនិយាយបានថា គឺគ្មានអ្នកសារព័ត៌មានណាម្នាក់ ដែលត្រូវបានគេសម្លាប់ទេ នៅពេលបច្ចុប្បន្ន មានតែការអនុវត្តច្បាប់។ អ៊ីចឹងការអនុវត្តច្បាប់ គឺជារឿងធម្មតាទេ ព្រោះសង្គមមានច្បាប់។ ប្រសិនបើសង្គមមានច្បាប់ ហើយមិនអនុវត្តច្បាប់ នោះទើបជាមិនធម្មតា។ និយាយអំពីសេរីភាពសារព័ត៌មាន ខ្ញុំក៏ចង់និយាយបន្តិចដែរ ប្រសិនបើយើងចង់បញ្ចប់អំពើនិទ្ទណ្ឌភាព គឺគ្មានអ្វីក្រៅពីការពង្រឹងការអនុវត្តច្បាប់នោះទេ»* ។

អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Without Border) បានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខ១៥១ ក្នុងចំណោម ១៨០ប្រទេស នៅក្នុងឆ្នាំ២០២៤ ហើយ ចំណាត់ថ្នាក់នេះបង្ហាញថា ស្ថានភាពនៃសេរីភាពសារព័ត៌មាន គឺមិនល្អ។ ជាក់ស្តែង កាលពីដើមខែតុលា អ្នកសារព័ត៌មានឯករាជ្យម្នាក់ គឺលោក ម៉ិច ដារ៉ា ត្រូវបានអាជ្ញាធរក្រុងភ្នំពេញ ចាប់ពន្ធនាគារ ដែលការចាប់ខ្លួននេះ ត្រូវបានអ្នកសារព័ត៌មានអន្តរជាតិថា ជាការ «សងសឹក» ព្រោះលោក ម៉ិច ដារ៉ា គឺជាអ្នកសារព័ត៌មានដ៏ល្បីផ្នែករាយការណ៍អំពីឧក្រិដ្ឋកម្មជួញដូរមនុស្ស និងអំពើពុករលួយនៅកម្ពុជា៕